# ប្រាសាទនាគព័ន្ធ ៖
# ″តីជិ″ ជម្រះមន្ទិលបាបកម្ម*

សុីយ៉ុន សុភារិទ្ធ
*Ph.D. candidate, University of California, Berkeley*

នៅសម័យអង្គរ យើងសង្កេតឃើញមានការកសាងប្រាសាទ ឬទីបូជាអ្វីមួយនៅកណ្តាលបារាយជាច្រើនទាំងក្នុងបរិបទព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា។ ទោះជាសង់នៅកណ្តាលបារាយដូចគ្នាក៏ដោយ សំណង់ទាំងនោះមាននាទីនិងលក្ខណៈស្ថាបត្យកម្មខុសប្លែកពីគ្នា។ លលៃជាប្រាសាទកសាងនៅលើខឿនខ្ពស់ នៅកណ្តាលបារាយ “ឥន្ទ្រតដាក” ដែលព្រះបាទយសោវរ្ម័នទី១ (គ.ស.៨៨៩-៩១០) ស្ថាបនាដើម្បីឧទ្ទិសកុសលថ្វាយមាតាបិតានិងជីដូនជីតា ដោយមានសាងព្រះរូបក្រោមទម្រង់ជាព្រះឥសូរនិងនាងឧមាផង។ ឯប្រាសាទមេបុណ្យនៅកណ្តាលបារាយទឹកថ្លាជាសំណង់ទាប មានតម្កល់ព្រះនារាយណ៍ដែលគេសន្មតថាផ្ទំនៅលើផ្ទៃសមុទ្រ ហើយផ្ទៃសមុទ្រនោះទៀតសោត គឺគេយកទឹកបារាយជាតំណាងតែម្តង។

រីឯប្រាសាទនាគព័ន្ធវិញ គេកសាងក្នុងបរិបទព្រះពុទ្ធសាសនានៅកណ្តាលបារាយ ជយតដាក (សព្វថ្ងៃហៅថា “វាលរាជដាក”)។ សំណង់នេះប្លែកពីសំណង់ឯទៀត ត្បិតជាស្រះទឹកនៅកណ្តាលបារាយ ឬអាចនិយាយបានថាជាស្រះទឹកនៅ កណ្តាលស្រះទឹក។ តាមការបកស្រាយរបស់លោកអ្នកប្រាជ្ញធំៗជាអាទិ៍លោក Louis Finot និងលោក Victor Goloubew ប្រាសាទនាគព័ន្ធនិម្មិតឱ្យស្រះសួគ៌នៅហិមល័យដែលហៅថា អនវតប្ត ឬក៏សព្វថ្ងៃហៅថា

* អត្ថបទនេះកែសម្រួលពីបទអន្តរាគមន៍មួយមានចំណងជើងដូចគ្នានេះដែរ ហើយដែលបានធ្វើឡើងនៅរាជបណ្ឌិត្យសភាកម្ពុជានៅថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០១១។ រូបភាពពីលើអាកាសយកមកកែលំអខ្លះពីឯកសារ Google Earth។ រូបលេខ១០ ស្រង់ចេញមកពី Boisselier ១៩៩៣ ឯរូបលេខ៨វិញបានមកពីលោក អន សុភាព។

“អនោតស្រះ”[១]។ ប៉ុន្តែបើយើងពិនិត្យសិក្សាចម្លាក់, សិលាចារឹកព្រមទាំងជំនឿទាក់ទងផ្សេងៗទៀតឱ្យបានល្អិតល្អន់ ប្រាសាទនាគព័ន្ធមិនមែនត្រឹមតែជាស្រះស្អាតដែលគេនិម្មិតនៅលើដីប៉ុណ្ណោះទេ តែជា “តីថិ” ដែលជាទីធ្វើកិច្ចពិធីជម្រះបាបមន្ទិលនានាដើម្បីឱ្យបានឆ្លងសមុទ្រសង្សារដល់បទមោក្សនៅជាតិកំណើតខាងមុខ។ ការកសាងប្រាសាទនេះពុំមែនពេលមួយនឹងឃើញធ្វើក៏ធ្វើទៅទេ គឺច្បាស់ជារៀបចំឡើងក្នុងក្របខណ្ឌនៃកម្មវិធីកសាងក្រុង, ហេដ្ឋារចនាសម្ព័ន្ធ, បូជនីយដ្ឋានទាំងអម្បាលម៉ាននៃព្រះបាទជ័យវរ្ម័នទី៧ *(គ.ស.១១៨១-វាង១២១០)* ជាប្រាកដ។

អ្វីទៅជាអនោតស្រះ? អ្វីទៅជា“តីថិ”? ហេតុអ្វីបានជាព្រះបាទជ័យវរ្ម័នទី៧ស្ថាបនាប្រាសាទនាគព័ន្ធនេះ? នៅទីនេះខ្ញុំនឹងពិចារណាដេញដោលរកដើមទងចំពោះសំណួរទាំងនេះ ត្បិតកម្មវត្ថុនៅទីនេះ គឺរកខ្លឹមសារ, អត្ថន័យនៃប្រាសាទនាគព័ន្ធទាំងក្នុងជំនឿ ដោយយកជំនឿនោះទៅដាក់នៅក្នុងបរិបទនៃប្រវត្តិសាសនាផង។ ដូច្នេះខ្ញុំមិនផ្តោតអារម្មណ៍ទៅលើចំណុចឯទៀត ដូចជានាទីជាធារាសាស្ត្រនៃវាលរាជដាកជាដើមទេ។ សូម្បីតែការរៀបរាប់អំពីរូបរាងនៃក្រុមសំណង់នាគព័ន្ធទាំងមូលដែលខ្ញុំនឹងធ្វើបន្ទាប់ទៅនេះ ក៏មិនមែនជាការបរិយាយក្បោះក្បាយដូចត្រូវធ្វើនៅក្នុងវិស័យស្ថាបត្យកម្មឡើយ គឺគ្រាន់តែរំឭកត្រួសៗអំពីភិនភាគទូទៅនៃសំណង់ដើម្បីសិក្សាអំពីនិម្មិតរូប[២]។

## ១. លក្ខណៈទូទៅនៃសំណង់ប្រាសាទនាគព័ន្ធ

នៅកណ្តាលបារាយជ័យតដាក *(៣.៥០០ម. x ៩០០ម.)* មានកំពែងទំនប់បួនជ្រុងស្មើ *(រូបលេខ១)* ដែលជាកំពែងក្រុមសំណង់នាគព័ន្ធ។

ចំពាក់កណ្តាលកំពែងទំនប់នីមួយៗមានជណ្តើរធ្វើពីថ្មបាយក្រៀម។ ជណ្តើរទាំងនោះបាញ់ទៅរកស្រះទឹកប្រាំដែលនៅកណ្តាល។ ក្រុមស្រះប្រាំនោះមានស្រះធំមួយនៅចំកណ្តាលគេ និងស្រះតូចជាងនោះតែទំហំប៉ុនៗគ្នាបួនទៀតអមនៅតាមទិសទាំងបួន ហាក់ដូចជាបរិវារនៃស្រះកណ្តាលនោះ។

---

[១] Finot et Goloubew 1923 : 401-405។ អនោតស្រះនេះនឹងលើកយកមកនិយាយនៅក្រោយនេះបន្តិច។

[២] សេចក្តីរៀបរាប់សង្ខេបនេះ ធ្វើឡើងយោងតាមអត្ថបទរបស់លោក Henri Marchal (Marchal 1926) និងរបស់លោក Maurice Glaize (Glaize 1940)។




រូបលេខ១១

## ស្រះធំកណ្ដាល

ស្រះធំកណ្ដាលជាស្រះមានរាងបួនជ្រុងស្មើ។ ជ្រុងនីមួយៗមានប្រវែងប្រមាណ៧០ម៉ែត្រ។ ពីមាត់ស្រះចុះទៅបាតស្រះមានជណ្ដើរធ្វើពីថ្មភក់គ្រប់ទិស។ នៅចំកណ្ដាលស្រះធំនេះមានប្រាង្គមួយស្ថិតនៅលើខឿនរាងមូល (រូបលេខ២)។ នៅផ្នែកខាងក្រោមនៃខឿននេះមាននាគពីររុំពាត់ជុំវិញ ហើយបើកពពារបែរទៅខាងកើត។ ចំណែកកន្ទុយនៃនាគទាំងពីររុំព័ន្ធគ្នាដែលជាដើមហេតុនាំឱ្យអ្នកស្រុកហៅប្រាសាទនេះថា“នាគព័ន្ធ”។ គួរកត់សម្គាល់ថា ខឿនដែលទ្រប្រាង្គផ្ទាល់ គឺត្របកឈូក១៦ត្របក[៣]។



រូបលេខ១២

[៣] ផ្កាឈូក១៦ត្របកនេះជាតំណាងឱ្យជំនុំនៃព្រះពោធិសត្វ១៦ព្រះអង្គ។

ប្រាង្គដែលនិយាយមកនេះមានទ្វារបួន ៖ ទ្វារខាងកើតចំហរ ចំណែកទ្វារបីទៀតបិទជិត។ នៅលើសន្ទឹកទ្វារបញ្ឆោតទាំងបីនោះ គេឆ្លាក់រូបព្រះលោកេស្វរៈឈរ (រូបលេខ១៣-៥)។ នៅបាតស្រះធំនេះ តាមទិសទាំងបួនជាប់នឹងប្រាង្គកណ្ដាលមានសំណង់និងចម្លាក់ផ្សេងទៀត ៖ ខាងកើតពីលើផ្លូវដើរក្រាលថ្មបាយក្រៀមមានចម្លាក់សេះមួយ ដែលមានមនុស្សកំពុងប្រតេងប្រតោងឡើងជិះសេះ (រូបលេខ១៦)។ កាលមិនទាន់ជួសជុល សេះនោះបាក់បែកច្រើនកំណាត់រកេតរកូតនៅលើដី ពុំដឹងថាកាលនាគព័ន្ធនៅមានដំណើរការ សេះនោះបែទៅខាងណាប្រាកដឡើយ។ ការដែលរៀបចំជួសជុលហើយ ដាក់ឱ្យបែរមុខទៅរកប្រាង្គកណ្ដាលនោះជាការយល់ឃើញរបស់លោក Henri Marchal ដែលកាន់អភិរក្សអង្គរនៅពេលនោះ។ ខាងត្បូងមានចម្លាក់នៅលើផ្ទាំងថ្មដែលអ្នកស្រុកហៅថា "ភ្នំពីរពាន់" ដែលអ្នកស្រាវជ្រាវគ្រប់គ្នាយល់ថាជារូបលិង្គ (រូបលេខ១៧)។ ខាងលិចវិញមានរូបចម្លាក់មនុស្សឬទេពអ្វីមួយទំនងជាផ្កាំ តែសឹករិចរិលខ្លាំងមិនអាចកំណត់ជាច់ណាត់ថាដូច្នោះប្រាកដទេ (រូបលេខ១៨)។ ខាងជើងមានជើងទម្រ៤ធ្វើពីថ្មភក់ តែមិនដឹងជាតម្កល់អ្វីឡើយពីមុននោះ។






ពីឆ្វេងទៅស្ដាំ ៖ រូបលេខ១៣, រូបលេខ១៤, រូបលេខ១៥ និងរូបលេខ១៦




ពីឆ្វេងទៅស្ដាំ ៖ រូបលេខ១៧ និងរូបលេខ១៨

*ស្រះតូចៗបួន*

ស្រះតូចៗទាំងបួនមានរាងបួនជ្រុងស្មើដូចស្រះធំដែរ ហើយជ្រុងនីមួយៗមានប្រវែងប្រមាណ ២៥ ម.។ ស្រះទាំងនេះមានបន្ទប់បង្ហូរទឹកដែលមានទទាំទឹកមកពីស្រះធំ។ ចុងទនីមួយៗមានរូបក្បាលសត្វឬមនុស្ស ៖ ចុងទស្រះខាងកើតជារូបក្បាលមនុស្ស, ខាងត្បូងមាត់សិង្ហ, ខាងលិចមាត់សេះ និងខាងជើងមាត់ដំរី (រូបលេខ១៩)។



*រូបលេខ១៩*

## ២. តើប្រាសាទនាគព័ន្ធជាអ្វី?

*អនោតស្រះ*

ដូចពោលបន្តិចមកហើយពីខាងដើមថា លោក Louis Finot និងលោក Victor Goloubew យល់ថាប្រាសាទនាគព័ន្ធ គឺជាស្រះសួគ៌នៅភ្នំហិមាល័យដែលមានឈ្មោះ ជាភាសាសំស្ក្រឹតថា “អនវតប្ត” នៅ លើដីខ្មែរ។ សព្វថ្ងៃខ្មែរមិនហៅតាមសំស្ក្រឹតទេ តែយកតាមឈ្មោះជាបាលីថា “អនោតត្ត” ហើយសរសេរជាទូទៅថា “អនោតស្រះ”។ ពាក្យសំស្ក្រឹត “អនវតប្ត” ឬបាលី “អនោតត្ត” ប្រែជាខ្មែរថា “មិនត្រូវកំដៅ”។

មានគម្ពីរខាងព្រះពុទ្ធសាសនាមហាយានជាច្រើនដែលនិយាយអំពីអនោតស្រះ ដូចជាគម្ពីរ “អភិធម៌កោស”

និងគម្ពីរ “ទីឃ៉ាគមសូត្រ”[៤]។គម្ពីអភិធម៏កោសនិយាយថាអនោតស្រះមានរាងបួនជ្រុងស្មើ ស្ថិតនៅឯភ្នំហិមាល័យក្នុងជំពូទ្វីប[៥]។ ចំណែកគម្ពីរទីឃ៉ាគមសូត្រមានសេចក្តីពន្យល់បន្ថែមថា គេហៅស្រះនេះថា “អនវតប្ត” ត្បិតនៅកណ្តាលស្រះមានព្រះរាជដំណាក់ដែលជាទីអាស្រ័យនៃស្តេចនាគមួយឈ្មោះអនវតប្ត[៦]។

ចំពោះសេចក្តីពន្យល់អំពីអនោតស្រះវិញ គម្ពីទីឃ៉ាគមសូត្រដែលខ្ញុំយកមកសង្ខេបយ៉ាងខ្លីដូច្នេះថា ៖

> នៅលើកំពូលភ្នំហិមាល័យមានស្រះទឹកមួយឈ្មោះ “អនវតប្ត”។ ស្រះនេះមានទឹកត្រជាក់ថ្លាយង់ ហើយជាទឹកបរិសុទ្ធឥតខ្ចោះ។ ជុំវិញស្រះមានជញ្ជាំងកំពែង៧ជាន់ធ្វើអំពីវត្ថុមានតម្លៃ៧យ៉ាង ដែលមានពណ៌ផ្សេងៗគ្នា។ បាតស្រះក្រាលទៅដោយគ្រាប់ខ្សាច់មាស។ នៅទៀបមាត់ស្រះមានឧទ្យាន និងទីសម្រាប់ងូតទឹកប្រកបទៅដោយដើមឈើគ្រប់ប្រភេទ មានផ្លែផ្កាក្រអូបឈ្ងុយឈ្ងប់ មានបក្សីគ្រប់បែបយ៉ាងយំប្រចឹកគ្នាលេងយ៉ាងសប្បាយ។ តាមជ្រុងនីមួយៗនៃអនវតប្តមានជណ្តើរចុះទៅក្នុងស្រះ។ ជណ្តើរប្រាក់មានបង្កាន់ដៃមាស រីឯជណ្តើរមាសមានបង្កាន់ដៃប្រាក់។ បង្កាន់ដៃនៅជុំវិញស្រះនេះមានផ្កាចម្រុះពណ៌ក្រហម, ខៀវ, លឿង និងស។
>
> នៅខាងកើតស្រះ មានទន្លេ *គង្គា* ដែលហូរចេញតាមមាត់គោធ្លាក់ទៅសមុទ្រខាងកើត។ ខាងត្បូង មានទន្លេ *សិន្ធុ* ហូរតាមមាត់សិង្ហធ្លាក់ទៅសមុទ្រខាងត្បូង។ ខាងលិច មានទន្លេ *វក្ខុ* ហូរតាមមាត់សេះធ្លាក់ទៅសមុទ្រខាងលិច។ ខាងជើង មានទន្លេ *សីតា* ហូរតាមមាត់ដំរីធ្លាក់ទៅសមុទ្រខាងជើង។
>
> នៅកណ្តាល *អនវតប្ត* មានព្រះរាជដំណាក់ដែលស្តេចនាគព្រះនាមអនវតប្តគង់នៅជាប្រចាំ។

មានគម្ពីរព្រះពុទ្ធសាសនាខ្លះទៀតបន្ថែមថាព្រះអរហន្ត និងព្រះបច្ចេកពុទ្ធឯទៀតដែលសម្រេចមោក្សធម៌

---

[៤] គម្ពីអភិធម៏កោសនេះរៀបរៀងនៅរវាងស.វ.ទី៥។ ចំណែកគម្ពីរទីឃ៉ាគមវិញ ព្រះសង្ឃព្រះនាម ពុទ្ធយសបកប្រែទៅជាភាសាចិននៅចុងរាជវង្សឈិន (គ.ស. ៣៨៤-៤១៧)។ ផ្នែកទីបួននៃទីឃ៉ាគមនិយាយអំពីលោកធាតុទាំងមូល ។ នៅទីនេះខ្ញុំនឹងលើកយកមកត្រង់ផ្នែកដែលនិយាយអំពីជំពូទ្វីប ពិសេសគឺត្រង់អនោតស្រះនោះតែម្តង។ សូមអាន Sadakata 1997: 39-33 ព្រមទាំង Howard 1986: 119-120 ។

[៥] Sadakata 1997: 31.

[៦] Howard 1986: 119-120។ នាគអនវតប្តជានាគដែលមិនជួបនូវរឿងអកុសលបីយ៉ាងដូចពពួកនាគឯទៀតនៅក្នុងជំពូទ្វីប៖

១.មិនត្រូវខ្យល់ក្តៅនិងខ្សាច់ក្តៅកំណាចធ្វើឱ្យរលួយរលេះដល់ឆ្អឹងនាំឱ្យឈឺពើតផ្សាខ្លាំង។

២. ខ្យល់កំណាចមិនអាចបក់នាំយកសម្លៀកបំពាក់គ្រឿងអលង្ការដែលនាំឱ្យខ្លួននាគទៅជាអាក្រាត។

៣.គ្រុឌមិនអាចមកចាប់យកធ្វើជាចំណីបាន។

ដោយអន្ទើ តែមិនទាន់សម្រេចនូវសម្មាសម្ពុទ្ធិញ្ញាណ (ពោលគឺពុំទាន់ត្រាស់ដឹងពេញលេញបរិបូណ៌) មកជំនុំធ្វើបរិសុទ្ធកម្មផ្សេងៗនៅអនោតត្តស្រះនេះ[៧]។

សេចក្ដីពន្យល់ក្នុងគម្ពីរទាំងនេះបញ្ជាក់ច្បាស់ហើយថានាគព័ន្ធជាអនោតត្តស្រះនោះឯង។ ប៉ុន្តែទោះជាយ៉ាងណាយើងកត់សម្គាល់ឃើញថា សេចក្ដីក្នុងគម្ពីរនិងការអនុវត្តជាក់ស្ដែងមានការឃ្លាងឃ្លាតគ្នា ពិសេសគឺស្រះខាងកើតនៃប្រាសាទនាគព័ន្ធដែលគម្ពីរនិយាយថាមានទន្លេគង្គាហូរចេញតាមមាត់គោ (គម្ពីរទីឃាគមសូត្រ) ឬ ដំរី (គម្ពីរអភិធម៌កោស) នោះ បើនៅនាគព័ន្ធវិញគឺហូរចេញតាមមាត់មនុស្ស[៨]។



*រូបលេខ១០*

តើការឆ្លាក់ក្បាលមនុស្ស ពោលគឺពុំមែនក្បាលសត្វកើតឡើងដោយសារខ្មែរជាន់នោះស្គាល់គម្ពីរផ្សេងពីនោះទៀតឬ?

សូម្បីតែគម្ពីរព្រះពុទ្ធសាសនាដែលខ្មែរស្គាល់ជំនាន់ក្រោយមកទៀត ជាអាទិ៍ក្នុងគម្ពីរត្រៃភូមិដែលនិយាយអំពី អនោតត្តស្រះក៏ពោលថាទន្លេហូរតាមមាត់សត្វទាំងបួនដែរ៖ គោ, សេះ, ដំរី និងសិង្ហ (សូមមើលរូបលេខ១០)។ ខាងក្រោមនេះ ជាតារាងប្រៀបធៀបគម្ពីរនានានិងចម្លាក់នៅប្រាសាទនាគព័ន្ធ៖

| *គម្ពីរទីឃាគម* | *គម្ពីរអភិធម៌កោស* | *ត្រៃភូមិ (ដើមសម័យកណ្ដាល)* | *ប្រាសាទនាគព័ន្ធ* |
|---|---|---|---|
| ខាងកើត, ទន្លេគង្គា,មាត់គោ | ដំរី | គោ | មនុស្ស |
| ខាងត្បូង, ទន្លេសិន្ធុ, មាត់សិង្ហ | គោ | សេះ | សិង្ហ |
| ខាងលិច, ទន្លេវក្សុ, មាត់សេះ | សេះ | ដំរី | សេះ |
| ខាងជើង, ទន្លេសីតា, ដំរី | សិង្ហ | សិង្ហ, | ដំរី |

[៧] Boisselier 1993: 23.

[៨] អ្នកការទូតចិនឈ្មោះជីវ តាក្វាន់ដែលមកអង្គរកាលពីគ.ស. ១២៩៦ យល់ថាក្បាលមនុស្ស ដែលជាទបង្ហូរទឹកខាងកើតជាព្រះកេសព្រះពុទ្ធ។ Zhou Daguan 2007: 48.

តារាងខាងលើនេះបង្ហាញថា ខ្មែរដែលសាងនាគព័ន្ធនោះធ្វើឱ្យទន្លេគង្គាហូរចេញ ពីអនោតស្រះតាមមាត់មនុស្សទៅទិសខាងកើតដែលជាទិសសំខាន់មួយនៅក្នុងជំនឿរបស់ខ្លួន។ ធម្មតាក្នុងជំនឿខាងព្រះពុទ្ធសាសនា គង្គាមានន័យត្រឹមតែជាទន្លេសួគ៌ប៉ុណ្ណោះ តែក្នុងព្រហ្មញ្ញសាសនាដែលខ្មែរជឿ និងប្រតិបត្តិជាច្រើនសតវត្សមុននោះមកទៀត គង្គា មិនមែនត្រឹមតែជាទន្លេសួគ៌ប៉ុណ្ណោះទេ គឺថែមទាំងជាទេពស្រី ដែលគេធ្លាប់គោរពមកដែរ[៩]។ មានន័យថាខ្មែរបុរាណស្គាល់នាងគង្គានិងទន្លេគង្គាច្បាស់ណាស់។ ការយកចម្លាក់ក្បាលមនុស្សជំនួសឱ្យក្បាលសត្វនេះ ខ្ញុំយល់ថាធ្វើដោយគ្មានមន្ទិលរារែកអ្វីសោះឡើយ គឺថាជាចេតនាពិតប្រាកដ។ ពោលឱ្យច្បាស់ជាងនេះទៅទៀត គឺខ្ញុំជឿថារូបមុខមនុស្សជាទបង្ហូរទឹកនៅទិសខាងកើតនោះជារូបនាងគង្គាតែម្ដង។ ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ បើទោះបីជាព្រះពុទ្ធសាសនារីកចម្រើនថ្កុំថ្កើងពេញទំហឹងក៏ដោយ ក៏សាសនាព្រាហ្មណ៍នៅតែមានឥទ្ធិពលនិងសន្ទុះជាធម្មតា។ ឧទាហរណ៍នៅប្រាសាទព្រះខ័នក៏មានអាចារ្យខាងនិកាយព្រះឥសូរធ្វើកិច្ចផ្សេងៗ ហើយក៏ទទួល ការឧបត្ថម្ភគាំទ្រពីព្រះមហាក្សត្រដែរ (K. 908, ល្បះទី១១០)។ ម្យ៉ាងទៀត ប្រាសាទនាគព័ន្ធនេះមិនមែនសាងឡើងផ្ដាច់មុខសម្រាប់តែពុទ្ធសាសនិកទេ គឺសម្រាប់មនុស្សទូទៅដែលក្នុងនោះមានអ្នកគោរពព្រះឥសូរ ឬព្រះនារាយណ៍ឬទេពណាដទៃទៀតជាធំ មិនខានឡើយ។ ហេតុនេះ ខ្ញុំយល់ថានៅក្នុងគំនិតខ្មែរ សាសនិកណាក៏ដោយ (ព្រហ្មញ្ញសាសនាក្ដី ពុទ្ធសាសនាក្ដី)តែងយល់ជាទូទៅដូចគ្នាថា គង្គា ជាទន្លេផងនិងជាទេពផង ជាហេតុញ៉ាំងឱ្យធ្លាក់ទន្លេគង្គាហូរចេញតាមមាត់នាងគង្គានោះ។

ការស្ថាបនាអនោតស្រះឱ្យឃើញស្ដែងនៅលើដីនេះ មិនមែនមានតែនៅស្រុកខ្មែរប៉ុណ្ណោះទេ។ កាលពីចុង ស.វ.ទី ៦ ដើមទី៧ អ្នកធម្មយាត្រាចិនឈ្មោះ Hiuan-tsang បានកត់ត្រាចូលក្នុងកំណត់ហេតុរបស់គាត់អំពីអនោតស្រះដែលគេសាងនៅនគររាជគ្រឹះ ក្នុងប្រទេសឥណ្ឌាដែរ[១០]។ អនោតស្រះនោះមាននាទីជាកន្លែងព្យាបាលជម្ងឺរាំរ៉ៃឱ្យជាសះស្បើយ។ ដោយផ្អែកលើកំណត់ត្រានេះ លោក Finot និងលោក Goloubew ក៏ស្នើថាប្រាសាទនាគព័ន្ធក៏មាននាទីជាកន្លែងព្យាបាលដូចគ្នាដែរ។ លោកទាំងពីរពន្យល់បន្ថែមថា ព្រះលោកេស្វរដែលជាព្រះមានមេត្រីករុណាសង្គ្រោះសត្វលោកផងទាំងពួង ហើយដែលមានចម្លាក់ច្រើនកន្លែងនៅប្រាសាទនាគព័ន្ធ ក៏មាននាទីជាអ្នកព្យាបាលឬអ្នកសង្គ្រោះដែរ[១១]។

## តីថជម្រះបាបកម្ម

នៅសម័យបុរាណ ខ្មែរស្គាល់ពាក្យសំស្ក្រឹត តីថ ហូរហែរមកដែរ។ ពាក្យនេះមានន័យថា កន្លែងមុជទឹក, ស្រះ

---

[៩] អ៊ូ គង្គា ២០១១។

[១០] Finot et Goulobew 1923: 403-404.

[១១] Finot et Goulobew 1923: 404-405។ សព្វថ្ងៃ គំនិតថានាគព័ន្ធជាកន្លែងដែលមានរុក្ខជាតិសម្រាប់ប្រើជាថ្នាំក៏នៅមានដែរ។ អ្នកស្រុកម្ដុំនោះនិយមទៅរកស្លឹកឬឫសឈើជាថ្នាំកែរោគនានានៅទីនេះ។ សូមអាន លឹម ស្រូ ២០០៨៖ ២៨-៣២។

ទឹក, ផ្លូវឬទីឆ្លងទឹកទៅត្រើយម្ខាងទៀត, ទីនៅតាមផ្លូវទឹកដែលរាក់ល្មមអាចដើរឆ្លងដោយជើងបាន[១២]។ តីរ្ថ ក្លាយមកពីពាក្យជាឫសថា “ត្ឫ” ដែលប្រែមកជាខ្មែរថា “ឆ្លង”។ នៅក្នុងជំនឿ គំនិតថា “ឆ្លង” នេះ គឺឈានពីធម្មតាទៅពិសិដ្ឋ, ពីលោកនេះទៅលោកខាងមុខ។ល។ មានសិលាចារឹកសំស្ក្រឹតនៅកម្ពុជាសម័យបុរាណជាច្រើនដែលប្រើកិរិយាស័ព្ទ “ត្ឫ” នេះ ដោយមានន័យថាឆ្លងពី ភពមួយទៅមួយទៀត។ ចំណែកពាក្យ“ឆ្លង” វិញ មានប្រើក្នុងកន្សោមពាក្យថា “ឆ្លងទន្លេ” ដែលអ្នកខ្លះយល់ថា “ឆ្លងដើម្បីមកចាប់កំណើតថ្មី”។ ក្នុងន័យនេះ ទារកដែលកើតមក ដូចជាបានជិះសំពៅឆ្លងមកចាប់កំណើតថ្មីនៅក្នុងចក្រវាឡយើងនេះដូច្នោះដែរ[១៣]។

តីថិពុំត្រឹមតែជាទីពិសិដ្ឋដែលចម្លងមនុស្សទៅសួគ៌ប៉ុណ្ណោះទេ គឺការឆ្លងនោះមានទៅមានមក ពោលគឺភ្ជាប់មនុស្ស និងទេព មានន័យថាឱ្យទេពឆ្លងមកជួយស្រោចស្រង់មនុស្សដែរ។ ក្នុងន័យនេះប្រាសាទ ឬទីដែលគេធ្វើកិច្ចពិធីក៏រាប់ថាជាតីថិដែរ ព្រោះទីនោះនាំឱ្យមនុស្ស និងទេពមានទំនាក់ទំនងគ្នាបាន។ ទោះជាយ៉ាងណាក៏ដោយ ពេលគេនិយាយអំពីតីថិ គេច្រើននឹកឃើញភ្លាមទៅដល់ទីពិសិដ្ឋដែលជាប់ទាក់ទងនឹងទឹក។ តីថិដែលគេយល់ថាពិសិដ្ឋជាងគេច្រើននៅទីណាដែលមានទឹកផុស ដូចជាក្បាលហុង, ជប់, ជាំ, ទីប្រសព្វនៃទន្លេឬ ស្ទឹង ឬក៏តាមចំណុចពិសេសខ្លះតាមដងផ្លូវទឹកជាដើម។ ដូច្នេះតីថិណាដែលល្បីខ្លាំងតែងមានមនុស្សម្នាផងទាំងឡាយធ្វើដំណើរទៅធ្វើកិច្ចផ្សេងៗ។ ហៅថា “តីថិយាត្រា”។ ធ្វើនេះ គឺដើម្បីជម្រះនូវបាបមន្ទិលនានា ហើយកើតបុណ្យកុសល ដែលអាចនឹងនាំឱ្យទៅដល់បទមោក្ស។ នៅប្រទេសឥណ្ឌាមានកន្លែងច្រើនណាស់ដែលរាប់ថាជាតីថិ ក្នុងនោះគេយល់ថា តីថិនៅប្រយាគនិងនៅ ពារាណសីមានភាពពិសិដ្ឋជាងទីណាទាំងអស់។

មានទេពកថាទាក់ទងនឹងតីថិនៅពារាណសីថា៖ ព្រះឥសូរបានកាត់ព្រះកេសទីប្រាំរបស់ព្រះព្រហ្ម ជាហេតុធ្វើឱ្យជាប់បាបកម្មខ្លាំងណាស់ ត្បិតជាអំពើបាបធ្វើទៅលើព្រាហ្មណ៍។ ដើម្បីជម្រះបាបនេះ ព្រះឥសូរធ្វើតីថិយាត្រាទៅច្រើនកន្លែង ពីតីថិមួយទៅតីថិមួយ ប៉ុន្តែនៅតែពុំអាចជម្រះមន្ទិលបាបកម្មនោះអស់សោះ។ លុះព្រះអង្គយាងមកដល់តីថិនៅក្រុងពារាណសីទើបជម្រះអស់នូវបាបកម្មនោះ[១៤]។

ខ្មែរបុរាណស្គាល់ជំនឿទាក់ទងនឹងតីថិច្បាស់លាស់ណាស់ រហូតដល់មានប្រើពាក្យនេះដាក់ឈ្មោះមនុស្ស (ឧ. K. 254) ព្រមទាំងភូមិករ (ឧ. K. 940) ផង។ មិនតែប៉ុណ្ណោះ ខ្មែរស្គាល់ដល់ទៅតីថិល្បីៗនៅប្រទេសឥណ្ឌាទៀត ជាពិសេសគឺប្រយាគដែលទើបនឹងនិយាយមកនេះបន្តិច ហើយដែលជាទីប្រសព្វមុខនៃទន្លេយមុនានិងគង្គា។ សិលាចារឹក

---

[១២] Eck 1981: 325.

[១៣] សូមអានសត្រាឈ្មោះ ព្រះកុណាកែវនាំងបី ដែលមានសេចក្តីពន្យល់ទាក់ទងនឹងរឿងនេះ។ តែយើងក៏ដឹងដែរថា មនុស្សទូទៅតែងយល់ថាគឺម្តាយនោះទេជាអ្នកឆ្លងទន្លេ។

[១៤] Eck 1981: 339-340.

ប្រែរូប (K. 806) ល្បះទី១៥៥ លើកសរសើរព្រះបាទរាជេន្ទ្រវរ្ម័នទី២ថា សត្រូវគ្រាន់តែទតឃើញព្រះខ័នទិងព្រះកាយរបស់ព្រះអង្គ យល់ថាពេលវេលាចុងក្រោយរបស់ខ្លួនមកដល់ហើយ។ លោតចូលទៅទីប្រសព្វមុខនៃទន្លេគង្គានិងយមុនា[១៥]។ ពាក្យថា “លោតចូលទៅទីប្រសព្វមុខ”នៅប្រយាគនេះ គឺចង់និយាយថាសត្រូវនោះស្លាប់មែន តែបានទៅសោយសុខនៅស្ថានសួគ៌ ដោយសារទីដែលលោតសម្លាប់ខ្លួននោះជាតីថ៌។

ចំណែកសិលាចារឹកព្រះខ័នល្បះទី៣៣លើកឡើងថា៖

> គេតែងចូលទៅ ប្រយាគ ដោយចិត្តជ្រះថ្លា ត្បិតនៅទីនោះមាន តីថ៌ ពីរដែលជម្រះមន្ទិលសត្វលោកផងទាំងឡាយ។ ចុះទម្រាំបើ ឆកជយគ្រី[១៦]ដែលមាន តីថ៌ ដ៏ឧត្តុង្គឧត្តម [ដល់ទៅបី] គឺព្រះដែលមានព្រះនេត្រជាផ្កាឈូក [ព្រះនារាយណ៍], ព្រះឥសូរនិងព្រះពុទ្ធទៅទៀត?[១៧]

ល្បះនេះរំឭកត្រង់ទៅប្រយាគតែម្តង ដែលជាទីប្រសព្វមុខនៃទនេទន្លេគង្គានិងយមុនា។ សូមកត់សម្គាល់ថាក្នុងល្បះនេះ ពាក្យតីថ៌មានន័យថា “ទន្លេ” ដែរ។ យើងនឹងពិភាក្សារឿងតីថ៌បី នៃនគរជ័យស្រីនៅខាងក្រោយ។

បើនិយាយពីជំនឿនិងកិច្ចប្រតិបត្តិទាក់ទងនឹងតីថ៌វិញ សិលាចារឹកកណ្តាលជុំ (K. 809) ចារនៅស.វទី៩, ល្បះទី៣៦ លើកសរសើរព្រាហ្មណ៍ម្នាក់ឈ្មោះសិវសោមថា ៖

> អ្នកណាដែលគ្រាន់តែបានប៉ះល្អងធូលីជើងគាត់ទាំងពីរដែលជាផ្កាឈូកហើយ អ្នកនោះនឹងទទួលផលបុណ្យ ដូចបានទៅមុជទឹកនៅតីថ៌គ្រប់ទិសទី[១៨]។

សិលាចារឹកមួយល្បះនេះឱ្យយើងយល់បានថា មនុស្សដែលប្រតិបត្តិធម៌ហ្មត់ចត់ឥតមានខ្ចោះប្រៀបបានទៅនឹងតីថ៌ដែរ។ ការប្រៀបធៀបនេះពុំមែនគ្មានដើមទងនោះទេ នៅប្រទេសឥណ្ឌា ជំនឿរបៀបនេះមាននិយាយនៅក្នុងគម្ពីរចាស់ៗដូចជាគម្ពីរតៃត្តិរិយ សំហិតា ដែលថា អ្នកដែលបានងូតទឹកនិងផឹកទឹកនៅតីថ៌ណាមួយ អ្នកនោះឯងក្លាយជាតីថ៌សម្រាប់អ្នកដែលមកគោរពគាត់ព្រមទាំងប្រតិបត្តិធម៌តាមឱវាទគាត់[១៩]។ ត្រង់នេះធ្វើឱ្យយើងកាត់យល់ថា ព្រាហ្មណ៍សិវសោមប្រាកដជាបានទៅងូតទឹកជម្រះមន្ទិលតាមតីថ៌ពិសិដ្ឋនានាមិនខានឡើយ ហើយគេយល់ថាដោយសារប្រការ

---

[១៥] Coedès 1937: 126.

[១៦] ឆករជយគ្រីនៅទីនេះសំដៅទៅបូជនីយដ្ឋានទាំងមូល ដែលមានប្រាសាទព្រះខ័ននិងវាលរាជដាក ដែលក្នុងនោះមាននាគព័ន្ធ។

[១៧] សេចក្តីប្រែនេះសម្រួលតាមការប្រែសិលាចារឹកព្រះខ័នលើកក្រោយបង្អស់ (Maxwell 2007: 31)។

[១៨] សម្រួលតាមការប្រែសិលាចារឹកកណ្តាលជុំដោយលោក George Coedès (Coedès 1937: 45)។

[១៩] Eck 1981: 327.

នេះ ខ្លួនគាត់ក្លាយទៅជាតីថិសម្រាប់អ្នកដទៃ។ លើសពីនេះទៅទៀត សិលាចារឹក១ល្បះនេះអាចឱ្យយើងសន្និដ្ឋាន ថានៅស្រុកខ្មែរកាលពី ស.វ.ទី៩មានការធ្វើតីថិយាត្រា គឺទៅមុជទឹកជម្រះបាបតាមទីនានាច្រើន ហើយបើពិនិត្យពាក្យមួយម៉ាត់ៗក្នុងល្បះនោះ គឺតីថិទាំងនោះត្រូវមានកិច្ចអភិសេក (តីថាភិសេក) ដើម្បីឱ្យក្លាយទៅជាទីពិសិដ្ឋ[២០]។

ចំណែកសិលាចារឹកប្រាសាទកែវ (K.277) ចារនៅសតវត្សទី១១ក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី១ នៅត្រង់បន្ទាត់ទី១៧ មាននិយាយសុំឱ្យសាធុជននានាជួយការពារទំនុកបម្រុងអ្នកធ្វើតីថិយាត្រាទាំងឡាយ[២១]។

សិលាចារឹកដូចបង្ហាញខ្លះៗពីខាងលើមក បញ្ជាក់ច្បាស់ថា ដំបូង តីថិសំដៅទៅកន្លែងមានទឹកសម្រាប់គេអាចមុជជម្រះបាប។ ទីនោះអាចជាបារាយ, ត្រពាំងនិងស្ទឹងជាដើម។ សិលាចារឹកប្រាសាទព្រៃប្រាសាទ (K.701) ចារនៅក្នុងរាជ្យព្រះបាទយសោវរ្ម័នទី១ បញ្ជាក់ថា បារាយយសោធរជាតីថិ។ ចំណែកសិលាចារឹកសំរោង K. 258 ចារនៅដើម ស.វ.ទី១២ក៏នៅតែហៅបារាយនោះថា វ្រះតីថិក្រិយសោធរតដាក ដដែល[២២]។ លើសពីនេះទៅទៀតនៅជិតបារាយដដែលនោះ ព្រះបាទយសោវរ្ម័នទី១ឱ្យគេស្ថាបនាអាស្រមសម្រាប់សាសនិកនិកាយព្រះឥសូរ, ព្រះនារាយណ៍និងព្រះពុទ្ធ ដើម្បីធ្វើកិច្ចពិធីផ្សេងៗ មានពិធីបុណ្យជូនតា ដែលសំស្ក្រឹតហៅថា ស្រាទ្ធផង។

ក្រៅពីនោះ សិលាចារឹកប្រាសាទបាទជុំ (K.266) ចារនៅគ.ស.៩៦០ និយាយថា មហេន្ទ្របវ៌ត ពោលគឺភ្នំគូលែន ជាប្រភពតីថិដែលមានទឹកហូរចុះមកចូលក្នុងស្រះមួយ[២៣]។ ស្រះទឹកនេះ គេហាមមិនឱ្យនរណាមុជ ឬយកដំរីមកលាងសំអាតក្នុងនោះឡើយ ក្រៅតែពីពួកព្រាហ្មណ៍អ្នកធ្វើកិច្ច[២៤]។ ការចាត់ទុកថាជាទីពិសិដ្ឋនេះ មិនមានអ្វីគួរឱ្យចំងល់ឡើយ ត្បិតទីនោះជាប្រភពទឹក។

ដូចយើងដឹងស្រាប់ហើយ តពីជួរភ្នំគូលែនទៅពាយព្យបន្តិចគឺជាភ្នំក្បាលស្ពានដែលជាប្រភពនៃស្ទឹងសៀមរាបដែរ។ នៅស.វ.ទី១១ ខ្មែរទៅឆ្លាក់រូបផ្សេងៗនៅតាមបាតស្ទឹងនឹងគែមស្ទឹងតាមភ្នំទាំងពីរនោះ។ ចម្លាក់នោះមានរូបទេពផ្សេងៗក្នុងព្រហ្មញ្ញសាសនា ហើយប្រការមួយដែលគួរកត់សម្គាល់គឺមានចម្លាក់រូបលិង្គច្រើនណាស់សមនឹងសិលាចារឹកហៅថា សហស្រលិង្គ មានន័យថា “លិង្គ១000”[២៥]។

បើត្រឡប់មកនាគព័ន្ធវិញ យើងឃើញថាល្បះទី ៣៣នៃសិលាចារឹកប្រាសាទព្រះខ័ននិយាយថា នគរជ័យស្រី

---

[២០] ត្រង់នេះហើយដែលសិលាចារឹកភាសាខ្មែរដូចជា K. 420 ប្រើពាក្យថា ច្នោង ពោលគឺ “ថ្លង” ៖ […] កាលច្នោងវ្រះត្រពាង […] (Coedès 1952: 162).

[២១] ពាក្យសំស្ក្រឹតដែលគេប្រើគឺ តីថយាត្រក (Coedès 1952: 157)។

[២២] Coedès 1952: 182

[២៣] ស្រះនោះទំនងជានៅម្តុំប្រាសាទបាទជុំ អាចជាស្រះស្រង់ ឬជាកសិន្ធុប្រាសាទបាតជុំខ្លួនឯងនោះតែម្តង។

[២៤] Coedès 1909: 240.

[២៥] Jacques 1999: 358-359.

នេះពិសិដ្ឋលើសប្រយាគទៅទៀតដោយសារមានតីថិដល់ទៅបី ពោលគឺព្រះពុទ្ធ, ព្រះនារាយណ៍ និងព្រះឥសូរ។ ល្បះទី៤១ ហៅប្រាសាទនាគព័ន្ធថា រាជ្យស្រី ថែមទាំងបញ្ជាក់ថានៅទីនោះមាន សហស្រលិង្គ (លិង្គ១000) ផង។ ចំណែកល្បះទី ១៧0 និយាយថា៖

> នៅក្នុង [តដាកនោះ] មានកោះអភិរមមួយស្រស់សង្ហាដោយសារមានស្រះពោរពេញទៅដោយទឹកដែលមានប្រភពពីតីថិនានា ហើយទឹកនេះជម្រះភក់បាបកម្មនៃអ្នកឯណាដែលមកជម្រះកាយ។ នេះគឺជាទូកដែលនាំឆ្លងមហាសមុទ្រភព[២៦]។

ល្បះទី១៧0 នេះនិយាយច្បាស់ថាទឹកនៃស្រះរាជ្យស្រីចេញមកពីប្រភពតីថិច្រើន រីឯល្បះទី ៤១និយាយអំពីស្រះរាជ្យស្រីប្រកបដោយលិង្គ១000។ តើលិង្គមួយ ពាន់ដែលនិយាយនោះនៅទីណា?

អ្នកស្រាវជ្រាវជាច្រើនយល់ថាលិង្គមួយពាន់ដែលសិលាចារឹកនិយាយ អាចជាដុំថ្មស្ថិតនៅខាងត្បូងប្រាង្គកណ្តាល[២៧] (សូមមើលរូបលេខ២៧ឡើងវិញ) ហើយបើយកតីថិបីដែលនិយាយនៅល្បះទី៣៣[២៨] មកគិត ដុំថ្មដែលមានរូបលិង្គនេះជាតីថិដែលជាព្រះឥសូរ។ ឯតីថិដែលជាព្រះនារាយណ៍គេយល់ថាគឺរូបមួយដែលនៅខាងលិចតែដែលសព្វថ្ងៃរិចរិលមើលរាងពុំសូវច្បាស់ដូចបានពោលពីខាងលើ (សូមមើលរូបលេខ២៨ឡើងវិញ)។ ចំណែកឯតីថិដែលជាព្រះពុទ្ធនោះគឺរូបព្រះលោកេសូរដែលនៅប្រាង្គកណ្តាលផង ដែលនិម្មិតជាសេះពាលាហផង។ សេចក្តីបកស្រាយនេះ សមហេតុផលគួរឱ្យយល់ស្របតាមបាន ក៏ប៉ុន្តែសូមកុំភ្លេចថា “លិង្គ១000” ដែលនិយាយមកនោះក៏អាចជាការរំឭកដល់លិង្គ១000នៅក្បាលស្ពានដែលជាប្រភពទឹកហូរចូលមកក្នុង ស្រះរាជ្យស្រីនេះដែរ។

ខ្ញុំយល់ថាប្រហែលជាយើងអាចគិតបានវែងឆ្ងាយជាងនេះទៀតក៏សឹងថាបាន បើយើងគិតមកសេចក្តីក្នុងសិលាចារឹកផ្សេងទៀតខ្លះ។ សិលាចារឹកក្បាលស្ពាន (K. 1011) ចារនៅគ.ស. ១0៥៤ (ឬ១0៥៥) និយាយអំពីការស្ថាបនាព្រះសហស្រលិង្គ[២៩] ចំណែកឯសិលាចារឹក K. 1012 នៅក្បាលស្ពានដដែលជៀបស្ទឹងសៀមរាបទៅនឹងទន្លេគង្គាដែលអាចជម្រះបាបកម្មទាំងអម្បាលម៉ានដូចជាទន្លេនៅស្ថានសួគ៌ដែរ[៣0]។ រីឯនៅនឹងបាតស្ទឹងវិញ យើងឃើញមានចម្លាក់

---

[២៦] នេះជាសេចក្តីប្រែសម្រួលតាមការបកប្រែរបស់លោក George Coedès (Coedès 1941: 300) និងរបស់លោក Thomas S. Maxwell (Maxwell 2007: 101)។

[២៧] Boisselier 1971: 99.

[២៨] សូមមើលខាងលើមុននេះ។

[២៩] Jacques 1999: 358-359.

[៣0] Jacques 1999: 361.

រូបព្រះនារាយណ៍ និងលិង្គព្រះឥសូរជាច្រើន[៣១]។ ត្រង់នេះ តើយើងអាចសន្និដ្ឋានបានទេថាស្ទឹងសៀមរាបជាប្រភពនៃតីថិពីរ ពោលគឺតីថិនៃព្រះនារាយណ៍ផងនិងព្រះឥសូរផង? តពីនោះមកទៀត តើស្រះរាជ្យស្រី (ស្រះនាគព័ន្ធ) អាចចាត់ទុកថាជាតីថិទីបី ពោលគឺតីថិព្រះពុទ្ធដែលជាអនោតស្រះបានឬទេ?

មួយវិញទៀត លោក Maurice Glaize កត់សម្គាល់ថា ស្រះកណ្ដាលនៃប្រាសាទនាគព័ន្ធពុំមានប្រឡាយឯណាមួយហូរចូលនៅក្នុងនោះឡើយ។ ផ្ទុយទៅវិញ ទឹកក្នុងស្រះនេះបានមកអំពីភ្លៀងផង ហើយជាទឹកដែលជ្រាបពីបាតស្រះខ្លួនឯងផង[៣២]។ តើគេធ្វើឱ្យមានទឹកនៅក្នុងស្រះរបៀបនេះដោយចេតនាឬ? បើដូច្នោះមែន មានន័យថា គេចាត់ទុកទឹកក្នុងស្រះនេះរបៀបជាទឹកផុស ឬទឹកជប់ ព្រោះទឹកប្រភេទនេះគេនិយមគោរពបូជាថាជាតីថិ ដូចនិយាយមកពីខាងលើ។

តាមលោក Maxwell សិលាចារឹកដែលផ្ទៀបកោះរាជ្យស្រីទៅនឹងទូកដែលនាំដល់បទមោក្សនោះឱ្យយើងយល់ថា ជ័យតដាកគឺជាសមុទ្រភព។ ដូច្នេះ ការធ្វើដំណើរឆ្លងពីកំពង់នៅមុខប្រាសាទព្រះខ័នទៅប្រាសាទនាគព័ន្ធ[៣៣] សំដៅដល់ការធ្វើដំណើរចាកផុតពីវដ្តសង្សារ[៣៤]។ ក្រៅពីល្បះទី១៧០ នៃសិលាចារឹកប្រាសាទព្រះខ័ននោះ យើងមានរូបចម្លាក់ដែរ ដែលបង្ហាញពីការឆ្លងសមុទ្រភព។ ចម្លាក់នោះគឺរូបសេះឈ្មោះ “ពាលាហ” ដែលនៅក្នុងស្រះ ព្រមទាំងចម្លាក់ហោជាងនៃប្រាង្គកណ្ដាល។ រូបទាំងពីរនេះមិនមែនជារូបទោលទីទៃពីគ្នាឡើយ គឺខ្ញុំយល់ថា ពិតជាមានទំនាក់ទំនងគ្នា។

សេះពាលាហជាអវតារបែងភាគនៃព្រះលោកេសូរដែលមកជួយសង្គ្រោះឈ្មួញដើរសំពៅ។ និទានរឿងនេះដោយសង្ខេបមកគឺ

> ពួកឈ្មួញសំពៅប្រាំរយនាក់លិចសំពៅហើយរសាត់អណ្ដែតទៅទើលើកោះមួយដែលមានពួកយក្ខិនីរស់នៅ។ ដោយដឹងថាមានមនុស្សមកហើយ យក្ខិនីទាំងនោះក៏នាំគ្នាដំណែងខ្លួនធ្វើជាស្រីក្មេងស្អាតៗដើម្បីទាក់ទាញឈ្មួញសំពៅទាំងនោះមកធ្វើជាប្ដី។ លុះនៅជាមួយគ្នាបានយូរបន្តិចមកនាយភេត្រាយល់មុនគេមុនឯងថា ភរិយាទាំងនោះសុទ្ធសឹងជាយក្ខិនី។ ដូច្នោះហើយក៏ប្រាប់គ្នីគ្នាឱ្យរកផ្លូវគេចខ្លួន។ អ្នកខ្លះក៏បន់ស្រន់ទឹកដល់ព្រះពោធិសត្វលោកេសូរសុំឱ្យព្រះអង្គជួយខ្លួនឱ្យរួចជីវិតខ្លះទៀតឈ្លក់វង្វេងនឹងសម្រស់យក្ខិនីក្លែងភេទទាំងនោះដោយពុំអើពើរកផ្លូវគេចខ្លួនឡើយ។ នៅពេលដែលបន់ស្រន់សុំឱ្យព្រះលោកេសូរជួយនោះ ព្រះអង្គក៏បង្ហាញព្រះកាយក្រោមទម្រង់ជាសេះសឈ្មោះ

---

[៣១] Boulbet et Dagens 1973: 9-16.

[៣២] Glaize 1940: 362.

[៣៣] ការឆ្លងនេះ អាចជាការឆ្លងពិតប្រាកដឬគ្រាន់តែជាកិច្ចពិធីអ្វីមួយនិម្មិតថាឆ្លង។ ខ្ញុំពុំហ៊ានអារកាត់ចំណុចនេះឡើយ។

[៣៤] Maxwell 2007: 101-102.

ពាលាហ ដើម្បីជួយចម្លងអ្នកសំពៅឱ្យរួចរស់ជីវិត។ តែគ្រានោះសេះពោធិសត្វផ្ដាំថាសុំកុំឱ្យងាកក្រោយឱ្យសោះ។ សេះក៏ហោះនាំអ្នកទាំងនោះមកដល់ត្រើយសុខវិញ។ អ្នកដែលបានឡើងជិះឬតោងសេះនោះហើយ តែងាក ក្រោយដោយស្ដាយស្រណោះភរិយាក្មេងនោះ ក៏ធ្លាក់មកជីវិញទៅជាចំណីនៃពួកយក្ខិនីទាំងនោះ[៣៥]។

ចម្លាក់សេះ ពាលាហនេះមិនមែនចង់បង្ហាញត្រឹមតែសាច់រឿងដែលព្រះពោធិសត្វជួយរំដោះ ពួកឈ្មួញសំពៅដែល វង្វេងលង់លក់ជាមួយនឹងយក្ខិនីឱ្យរួចរស់ជីវិតពីគ្រោះមរណាប៉ុណ្ណោះទេ តែគឺចង់បង្ហាញថា ព្រះលោកេសូរជួយរំដោះឈ្មួញសំពៅនោះឱ្យរួចពីសេចក្ដីស្លាប់ក្នុងសមុទ្រសង្សារ ហើយនាំឱ្យបានដល់ត្រើយនិព្វានផង។ នៅពេលអ្នកសំពៅឆ្លងទៅដល់ត្រើយ ពោលគឺប្រាង្គកណ្ដាលនៃប្រាសាទ យើងឃើញមានចម្លាក់នៅតាមហោជាង ដែលបង្ហាញអំពីដំណើររបស់ព្រះពុទ្ធអង្គរកាលយាង "ឆ្លង" សមុទ្រសង្សារទៅកាន់ត្រើយនិព្វាន។

ហោជាងនៅប្រាង្គកណ្ដាលនេះត្រូវមើលពីខាងត្បូងមុន បន្ទាប់មកមើលខាងជើង។ បន្ទាប់មកទៀត ទើបមើលហោជាងខាងកើត បញ្ចប់ទៅដោយហោជាងខាងលិច។ ដោយសារចម្លាក់ខ្លះសិករិចរិលខ្លាំង ខ្ញុំសូមសិក្សាប្រៀបធៀបជាមួយហោជាងនៅប្រាសាទវត្តនគរ (កំពង់ចាម) ដែលគេឆ្លាក់នៅស.វទី១៦[៣៦] ដោយសារចម្លាក់នៅវត្តនគរបង្ហាញឈុតព្រមទាំងគំនិតដូចគ្នាអំពីដំណើរព្រះពុទ្ធអង្គទៅដល់និព្វាន។ នៅវត្តនគរចម្លាក់ខាងលិចបង្ហាញព្រះពោធិសត្វកាលព្រះអង្គគង់នៅស្ថានតុសិត (រូបលេខ១១)។ រូបនេះហាក់ដូចជាត្រូវនឹងគំនិតហោជាងនាគព័ន្ធខាងត្បូងដែលយើងឃើញមានទេពគង់ក្នុងវិមានអាកាសមួយ ហើយដែលមានទេពនានាហោះទ្រពីក្រោម(រូបលេខ១២)។ ហោជាងវត្តនគរខាងជើងនិយាយពីកាលព្រះសិទ្ធត្ថយាងទៅសាងព្រះផ្នួស (រូបលេខ១៣) ដែលត្រូវនឹងនាគព័ន្ធខាងជើង (រូបលេខ១៤), វត្តនគរខាងត្បូងបង្ហាញរូបព្រះអង្គកាត់ព្រះកេសា (រូបលេខ១៥) ត្រូវនឹងនាគព័ន្ធខាងកើត (រូបលេខ១៦)។ ហោជាងវត្តនគរខាងកើតបង្ហាញឈុតព្រះអង្គផ្ចាញ់មារ(រូបលេខ១៧)។ នៅនាគព័ន្ធវិញ ពុំមានរូបឈុតនោះតែម្ដងទេ តែបើជាគំនិត គឺហាក់ដូចជាប្រហាក់ប្រហែលគ្នា ត្បិតយើងឃើញថាទេពបីអង្គ (រូបលេខ១៨) ពោលគឺព្រះនារាយណ៍នៅខាងឆ្វេង, ព្រះព្រហ្មនៅខាងស្ដាំ[៣៧] ហែរហមអបអរសាទរនឹងទេពធំមួយដែលគង់ពីលើ ហើយដែលខ្ញុំយល់ថាជាព្រះពុទ្ធអង្គ ត្បិតរូបរបៀបនេះពុំពិសេសអ្វីតែនឹងនាគព័ន្ធឡើយ គឺយើងតែងឃើញមានឆ្លាក់នៅប្រាសាទផ្សេងៗ ទៀតច្រើនកន្លែងក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ដូចជានៅប្រាសាទតាព្រហ្ម, តាសោម, បន្ទាយក្ដីជាដើម។

សូមបញ្ជាក់ថា ឧកញ៉ាយសដែលមកកសាងកែកុនប្រាសាទវត្តនគរនៅស.វ.ទី១៦ ដោយឆ្លាក់ហោជាងថ្មីដូច

---

[៣៥] សូមអាន Meech-Pekarik 1981: 111-128 និង Goloubew 1927: 223-237។

[៣៦] សូមអាន Giteau 1967។

[៣៧] នៅកណ្ដាលទេពធំទាំងពីរឃើញមានរូបមួយ ពុំដឹងថាជាតំណាងឱ្យទេពនិករតូចតាចឬជាអសោរដែលមកប្រណម្យសម្ពឹងទៅលើ។



រូបលេខ១១



រូបលេខ១២



រូបលេខ១៣



រូបលេខ១៤


រូបលេខ១៥


រូបលេខ១៦


រូបលេខ១៧


រូបលេខ១៨

ទើបនឹងនិយាយមកនេះ មានទុកសិលាចារឹកមួយ (ក្នុងនោះផ្នែកជាភាសាបាលីវែងជាងភាសាខ្មែរ) នៅគ.ស.១៥៦៦ ដែលមាននិយាយអំពីគំនិតចង់ត្រាស់ដឹងដូចគ្នាដែរ[៣៨]។

## ៣. ប្រាសាទនាគព័ន្ធនិងព្រះបាទជ័យវរ្ម័នទី៧

ព្រះពុទ្ធសាសនាមហាយានដែលមានការគោរពព្រះលោកេស្វរគួរឱ្យកត់សម្គាល់នោះ រីកចម្រើននិងមានសន្ទុះខ្លាំងក្លានៅក្រោមរាជ្យព្រះបាទជ័យវរ្ម័នទី៧។ ព្រះរាជាអង្គនេះហាក់ដូចជាគោរពព្រះលោកេស្វរខ្លាំងណាស់ ដោយសារនេះជាទេពដែលជួយសង្គ្រោះសត្វលោកទាំងពួង។ និយាយម្យ៉ាងទៀតគឺថា ទេពនេះហាក់ដូចជាគំរូនៃព្រះរាជាតែម្តង។ ល្បះទី១៣នៃសិលាចារឹកសៃហ្វុង (K. 368) និយាយថា ៖

> *រោគក្នុងខ្លួនរបស់ប្រជារាស្ត្រធ្វើឱ្យព្រះអង្គ (ព្រះបាទជ័យវរ្ម័នទី៧) ឈឺចាប់ខ្លាំងជាងរោគរបស់ព្រះអង្គផ្ទាល់ទៅទៀត ត្បិតទុក្ខសោកប្រជារាស្ត្រនេះឯងដែលជាទុក្ខសោកព្រះរាជា ពោលគឺពុំមែនទុក្ខសោកផ្ទាល់នៃព្រះរាជានោះទេដែលជាធំ*[៣៩]។

ជាការជាក់ស្តែងក៏យើងដឹងហើយថា ព្រះបាទជ័យវរ្ម័នទី៧ បានកសាងហេដ្ឋារចនាសម្ព័ន្ធដែលមានលក្ខណៈជាសង្គមកិច្ចនិងសុខាភិបាលយ៉ាងច្រើន មានមន្ទីរពេទ្យនិងសាលាសំណាក់ជាដើម។ ចំពោះគំនិតទៅបរលោកនាយវិញ ក៏យើងឃើញថាព្រះអង្គខ្វល់ខ្វាយក្នុងការជួយចម្លងប្រជារាស្ត្រឱ្យ "ឆ្លង" ផុតសមុទ្រភព រហូតបានដល់បទមោក្ស ដូចមាននិយាយនៅក្នុងល្បះទី ៤៦ នៃសិលាចារឹកសៃហ្វុងដដែលនោះ ៖

> [....] *សត្វលោកអម្បាលម៉ានដែលធ្លាក់ទៅក្នុងមហាសមុទ្រភព សូមឱ្យខ្ញុំអាចជួយស្រោចស្រង់ដោយកុសលដែលខ្ញុំបានសាងមកនេះ*[៤០]។

សិលាចារឹកប្រាសាទព្រះខ័នដែលនិយាយនៅខាងលើក៏មានបញ្ជាក់ថាជយស្រីកសាងនៅលើសមរភូមិមួយដែលជាបទៅដោយឈាម (ល្បះទី៣២)។ ត្រង់នេះបង្ហាញថា ព្រះបាទជ័យវរ្ម័នទី៧មានចេតនាពិតប្រាកដ ក្នុងការកែប្រែ

---

[៣៨] Filliozat 1969: 93-106.

[៣៩] សម្រួលមកពី Finot 1903: 30។

[៤០] Finot 1903: 33។ "កុសល" នៅទីនេះសំដៅលើមន្ទីរពេទ្យដែលព្រះអង្គបានសង់។

ទីដែលធ្លាប់កាប់សម្លាប់គ្នាឱ្យទៅជាទីពិសិដ្ឋបំផុត អាចរំដោះមនុស្សម្នាផងទាំងឡាយ រួមទាំងអ្នកដែលស្លាប់នៅទីនោះផង ឱ្យរួចផុតដល់ស្ថានបរមសុខ។

សេចក្តីសង្កេតចុងក្រោយរបស់ខ្ញុំទាក់ទងនឹងការរៀបចំដែនដីទាំងមូល ថ្វីត្បិតតែខ្ញុំពុំច្បាស់ថានេះជាចេតនាឬមួយជាការចៃដន្យ ៖ នគររាជ្យស្រីទាំងមូលដែលបញ្ចូលប្រាសាទព្រះខ័ននិងវាលរាជដាកជាមួយគ្នានេះ ស្ថិតនៅឦសាននៃក្រុងអង្គរធំដែលរៀបចំជាក្រោយបន្តស់ដោយព្រះបាទជ័យវរ្ម័នទី៧ដែរ។ បើយកតែមណ្ឌលមកគិតក៏ឃើញថានាគព័ន្ធដែលជាកោះរាជ្យស្រីក៏ស្ថិតនៅឦសាននៃប្រាសាទបាយ័ន្តដែរ (រូបលេខ១៩)។ ដូចយើងដឹងហើយ មានការសិក្សាជាច្រើនដែលបង្ហាញថា ឦសាន តាំងតែពីបុរាណកាលមកទល់បច្ចុប្បន្ន ជាទិសនៃការចាប់ជាតិក្នុងសុគតិភព[៤១]។




រូបលេខ១៩

[៤១] ចំពោះសារសំខាន់នៃទិសឦសាននៅសម័យបុរាណ សូមអាន Paris 1941។ បើមាននិយាយបញ្ចូលទាំងសម័យឥឡូវផង សូមអាន Ang 2004 និង អាំង ជូលាន ២០០៧។

សង្ខេបយ៉ាងខ្លីមួយម៉ាត់មក នាគព័ន្ធដែលហៅថា រាជ្យស្រី ហើយដែលជាមណ្ឌលរបស់ជយតដាក[៤២] គឺជាតីថិ ក្នុងន័យទូលំទូលាយនៃ នគរជយស្រីទាំងមូល[៤៣]។ មិនមែនជាការចៃដន្យឡើយដែលស្ថាបនិកនគរជ័យស្រីទាំងមូលនេះជាព្រះបាទជ័យវរ្ម័នទី៧ ត្បិតទាល់តែមនុស្សដែលមានទស្សនវិស័យកម្រិតនេះទើបអាចកែច្នៃទឹកដីឬ ភូមិសាស្ត្រធម្មជាតិឱ្យទៅជាតីថិដ៏ធំធេងយ៉ាងនេះបាន។

[៤២] សូមបញ្ជាក់ម្តងទៀតថាឈ្មោះបារាយនោះសព្វថ្ងៃគឺ “វាលរាជដាក”។

[៤៣] ខ្ញុំបានជម្រាបនៅកំណត់យោងលេខ១៧ហើយថា សិលាចារឹកនិយាយពី នគរជយស្រី ក្នុងន័យថាជាបូជនីយដ្ឋានទាំងមូលដែលមានប្រាសាទព្រះខ័ននិងវាលរាជដាកដែលក្នុងនោះមាននាគព័ន្ធផង។

# ឯកសារពិគ្រោះ

*ភាសាខ្មែរ*

លឹម ស្រ៊ូ, ២០០៨, "ប្រាសាទនាគព័ន្ធនិងជំនឿក្នុងការព្យាបាលជម្ងឺ", *កម្រងអត្ថបទក្នុងបណ្ដាញពត៌មានវប្បធម៌ខ្មែរ*, ភ្នំពេញ, ២៨-៣២។

អ៊ុំ គង្គា, ២០១១, *ព្រះគង្គា*, និក្ខេបបទបញ្ចប់បរិញ្ញាបត្របុរាណវិទ្យា, ភ្នំពេញ។

អាំង ជូលាន, ២០០៧, "សង្ខេបជំនឿលើព្រះយមរាជនៅប្រទេសកម្ពុជា", *ព្រឹត្តិបត្របុរាណវិទ្យា១*, ភ្នំពេញ៖ ២៥-៣៨។

*ភាសាបរទេស*

Ang, Ch., 2004, "La mort-renaissance en abstraction iconographique", *Udaya* 5, Phnom Penh: 85-98.

Boisselier, J., 2003, *The Wisdom of the Buddha*, Harry N. Abrams, New York.

Boisselier, J., 1970, "Pouvoir royal et symbolisme architectural: Neak Pean et son importance pour la royauté angkorienne", *Arts Asiatiques* 21: 91-108.

Boulbet, J. et Dagens, B., 1973, "Les sites archéologiques de la région du Bhnaṃ Gūlen (Phnom Kulen)", *Arts Asiatiques* 27: 3-130.

Coedès, G., 1908, "Les inscriptions de Bàt Čuṃ (Cambodge)", *Journal Asiatique* 12: 213-254.

Coedès, G., 1932, "À la recherche du Yaçodharāçrama", *Bulletin de l'École Française d'Extrême-Orient* 32: 84-108.

Coedès, G., 1937, *Inscriptions du Cambodge*, vol. 1, Imprimerie d'Extrême-Orient, Hanoi.

Coedès, G., 1941, "La stèle du Práḥ Khằn d'Aṅkor", *Bulletin de l'École Française d'Extrême-Orient* 4: 255-301.

Coedès, G., 1942, *Inscriptions du Cambodge*, vol. 2, Imprimerie d'Extrême-Orient, Hanoi.

Coedès, G., 1952, *Inscriptions du Cambodge*, vol. 4, École Française d'Extrême-Orient, Paris.

Eck, D. L., 1981, "India's 'Tirthas': 'Crossing' in Sacred Geography", *History of Religions* 20, n. 4: 323-344.

Filliozat, J., "Une inscription cambodgienne en pāli et en khmer de 1566 (K 82 Vatt Nagar)", *Comptes-rendus des séances de l'Académie des Inscriptions et Belles-Lettres* 113, n. 1: 93-106.

Finot, L., 1903, "L'inscription sanskrite de Say-Fong", *Bulletin de l'École Française d'Extrême-Orient* 3: 18-33.

Finot, L. et Goloubew, V., 1923, "Le symbolisme de Nǎk Pǎn", *Bulletin de l'École Française d'Extrême-Orient* 23: 401-405.

Giteau, M., 1967, "Note sur les frontons du sanctuaire central de Vatt Nagar", *Arts Asiatiques* 16, Paris: 125-139.

Glaize, M., 1940, "Essai sur la connaissance de Nǎk Pǎn après anastylose", *Bulletin de l'École Française d'Extrême-Orient* 40, n. 2: 351-362.

Goloubew, V., 1927, "Le cheval Balaha", *Bulletin de l'École Française d'Extrême-Orient* 27: 223-237.

Howard, A. F., 1986, *The Imagery of the Cosmological Buddha*, E. J. Brill, Leiden.

Jacques, C., 1999, "Les inscriptions du Phnoṃ Kbal Spãn (K 1011, 1012, 1015 et 1016)", *Bulletin de l'École Française d'Extrême-Orient* 86, Paris: 357-374.

Marchal, H., 1926, "Notes sur l'architecture de Nǎk Pǎn, *Bulletin de l'École Française d'Extrême-Orient* 26 : 1-10.

Maxwell, T. S., 2007, "The Stele Inscription of Preah Khan, Angkor: Text with Translation and Commentary", *Udaya* 8: 1-113.

Meech-Pekarik, J., 1981, "The Flying White Horse: Transmission of the Valāhassa Jātaka Imagery from India to Japan", *Artibus Asiae* 43, No. 1/2: 111-128.

Paris, P., 1941, "L'importance rituelle du Nord-Est et ses applications en Indochine", *Bulletin de l'École Française d'Extrême-Orient* 41 : 303-333.

Sadakata, A., 1997, *Buddhist Cosmology: Philosophy and Origins*, Kosei Publishing Co., Tokyo.

Zhou Daguan, 2007, *A Record of Cambodia*: *The Land and Its People*, tran. Peter Harris, Silkworm Books, Bangkok.

## សង្ខេប

## ប្រាសាទនាគព័ន្ធ ៖ "តីរ្ថ" ជម្រះមន្ទិលបាបកម្ម

*ស៊ីយ៉ុន សុភារិទ្ធ*

នាគព័ន្ធជាក្រុមស្រះមួយស្ថិតនៅចំកណ្ដាលបារាយ ជយតដាក ដែលសាងឡើងនៅចុងស.វ.ទី១២។ ក្រៅអំពីការប្រើប្រាស់ក្នុងប្រព័ន្ធធារាសាស្ត្រកសិកម្ម នាគព័ន្ធមាននាទីធំក្នុងសាសនាដោយដើរតួជា តីរ្ថ ពោលគឺស្រះទឹកពិសិដ្ឋសម្រាប់សាសនិកមកលាងជម្រះខ្លួនឱ្យស្អាតពីភក់ជ្រាំដែលជាមន្ទិលបាប។ និម្មិតរូបនៃទីនេះគឺជា "សំពៅ" ចម្លងសត្វលោកឱ្យផុតពី "សមុទ្រសង្សារ" ស្របតាមព្រះហឫទ័យនៃព្រះបាទជយវរ្ម័នទី៧ដែលចង់ឱ្យមនុស្សលោកឆ្លងដល់ត្រើយនិព្វាន។ ព្រះរាជប្រាថ្នានេះបានសម្រេចដោយអន្លើ តាមរយៈការកសាងទីក្រុងពិសិដ្ឋមួយហៅជំនាន់នោះថា នគរីជយស្រី ហើយដែលចែកចេញជាពីរផ្នែកធំៗ ៖ ប្រាសាទព្រះខ័ននិងជយតាដាកនៅខាងកើត ដែលមាននាគព័ន្ធនៅក្នុងនោះ។



**Abstract**

*Neak Pean: A Purifying* Tīrtha

*Siyonn Sophearith*

Neak Pean temple is an ensemble of ponds, located in the middle of a late 12th century reservoir, called *Jayataṭāka*. Besides its hydraulic agricultural role, the ensemble played a significant religious role as a *tīrtha* (a sacred bathing place) whose water was understood to purge all sins of those who ritually washed themselves there. It also served metaphorically and symbolically as a "boat" for crossing "the ocean of existence." This function passionately emphasized by King Jayavarman VII, whose intention was to save all beings from the ocean of existence. The King's strivings were partly realized by the construction of a "sacred city", known by its ancient name *nagarī jayaśrī* in Angkor, which is comprised of two main elements: Preah Khan temple and *Jayataṭāka* to the east, in the middle of which Neak Pean is located.



**Résumé**

*Neak Pean: un* tīrtha *purificatoire*

Siyonn Sophearith

Neak Pean est un ensemble de bassins creusés au milieu d'un réservoir du nom de *Jayataṭāka*,

construit à la fin du 12ème siècle. A part sa fonction hydraulique agricole, il jouait un rôle crucial de *tīrtha* (bain sacré) dont l'eau est sensée laver le baigneur de tous les péchés. Métaphoriquement et symboliquement, il s'agit d'un bateau traversant l'océan des existences et répond à l'ardent souhait de Jayavarman VII de voir les êtres en être délivrés. Les efforts du roi ont en parti abouti en la construction d'une "cité sacrée" connue sous le nom de *nagarī jayaśrī* à Angkor, et composée de 2 principaux éléments : le temple de Preah Khan ainsi que le *Jayataṭāka* portant en son centre le temple de Neak Pean.